ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកាត់ផ្ទៃដីទំហំសរុប ១ ១២៥ ០០០ (មួយលានមួយរយម្ភៃប្រាំពាន់) ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរឬស្សី៣ និងភូមិស្រែស្ពៅ១ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ចេញពីដីសារពើភ័ណ្ឌរបស់រដ្ឋបាលខេត្តក្រចេះ និងការធ្វើអនុបយោគ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



៥

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្ដីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរលេខ០៦ សរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ ស្ដីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១:_**

កាត់ផ្ទៃដីទំហំសរុប ១ ១២៥ ០០០ (មួយលានមួយរយម្ភៃប្រាំពាន់) ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរឫស្សី៣ និងភូមិស្រែស្ដៅ១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ (ដីអតីតព្រលានយន្តហោះខេត្ត) ចេញពីដីសារពើភ័ណ្ឌរបស់រដ្ឋបាលខេត្តក្រចេះ ក្នុងនោះ÷

- ធ្វើអនុបយោគលើផ្ទៃដីទំហំ ៤៧៨ ៨៤០ (បួនរយចិតសិបប្រាំបីពាន់ប្រាំបីរយសែសិប) ម៉ែត្រការ៉េ ពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៦គ្រួសារ ស្មើនឹង ១៣១ក្បាលដី។
- រក្សាទុកផ្ទៃដីទំហំ ៦៤៦ ១៦០ (ប្រាំមួយរយសែសិបប្រាំមួយពាន់មួយរយហុកសិប) ម៉ែត្រការ៉េ ជាដីសាធារណៈរបស់រដ្ឋដដែល និងចុះបញ្ជីទីតាំងដីនេះ ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់សាងសង់សាកលវិទ្យាល័យក្រចេះ ចំនួន ៣ក្បាលដី លើផ្ទៃដីទំហំ ៥២៦ ៨៥៥ (ប្រាំរយម្ភៃប្រាំមួយពាន់ប្រាំបីរយហាសិបប្រាំ) ម៉ែត្រការ៉េ និងជូនសាលាខេត្តក្រចេះ មន្ទីរពាណិជ្ជកម្មខេត្តក្រចេះ មន្ទីរមុខងារសាធារណៈក្រចេះ និងការិយាល័យទី២កងទ័ពជើងគោក ចំនួន ៤ក្បាលដី លើផ្ទៃដីទំហំ ១១៩ ៣០៥ (មួយរយដប់ប្រាំបួនពាន់បីរយប្រាំ) ម៉ែត្រការ៉េ។

**មាត្រា២:_**

ផ្ទៃដីដែលបានធ្វើអនុបយោគដូចមានកំណត់ក្នុងមាត្រា១ខាងលើនេះ ត្រូវចាត់នីតិវិធីបន្តដោយក្រសួងមហាផ្ទៃ និងរដ្ឋបាលក្រុងក្រចេះ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តក្រចេះ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋឱ្យទទួលបានកម្មសិទ្ធិស្របច្បាប់ និងស្របតាមនីតិវិធីជាធរមាន។



៩

**មាត្រា៣:_**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:_**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤កើត ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងដីទំហំសរុប ១ ១២៥ ០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរឫស្សី៣ និងភូមិស្រែស្តៅ១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ ស្នើសុំកាត់ចេញពីដីសារពើភ័ណ្ឌរបស់រដ្ឋបាលខេត្តក្រចេះ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ




តារាងនិយាមកាព្រំដី

Projection UTM Zone 48N

Datum WGS 1984

| ID | E | N |
|---|---|---|
| 2 | 615255.165 | 1381644.600 |
| 3 | 615249.136 | 1381633.501 |
| 4 | 614870.557 | 1380925.632 |
| 5 | 614844.009 | 1380869.529 |
| 6 | 614822.430 | 1380835.849 |
| 7 | 614184.000 | 1379647.000 |
| 8 | 613831.000 | 1379836.000 |
| 9 | 614419.523 | 1380939.329 |
| 10 | 614202.000 | 1381056.000 |
| 11 | 614438.000 | 1381497.000 |
| 12 | 614656.112 | 1381379.551 |
| 13 | 614823.914 | 1381687.653 |
| 14 | 614837.833 | 1381709.376 |
| 15 | 614844.326 | 1381718.366 |
| 16 | 614862.821 | 1381759.834 |
| 17 | 615013.000 | 1382039.000 |

ផែនទីនិងតារាងនិយាមកាឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..១៧៦..អនក្រ.បក..ចុះថ្ងៃទី..២៦...ខែ..កញ្ញា...ឆ្នាំ២០២៥




| ID | E | N |
|---|---|---|
| 2 | 615255.165 | 1381644.600 |
| 3 | 615249.136 | 1381633.501 |
| 4 | 614870.557 | 1380925.632 |
| 5 | 614844.009 | 1380869.529 |
| 6 | 614822.430 | 1380835.849 |
| 7 | 614184.000 | 1379647.000 |
| 8 | 613831.000 | 1379836.000 |
| 9 | 614419.523 | 1380939.329 |
| 10 | 614202.000 | 1381056.000 |
| 11 | 614438.000 | 1381497.000 |
| 12 | 614656.112 | 1381379.551 |
| 13 | 614823.914 | 1381687.653 |
| 14 | 614837.833 | 1381709.376 |
| 15 | 614844.326 | 1381718.366 |
| 16 | 614862.821 | 1381759.834 |
| 17 | 615013.000 | 1382039.000 |